**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យ ឌី ម៉ុនហ្វត កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជននិងកីឡា
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# **សម្រេច**

**មាត្រា១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **«សាកលវិទ្យាល័យ ឌឺ ម៉ុនហ្វត កម្ពុជា»** សរសេរជាអក្សរកាត់ថា «ស.ឌ.ម.ក» និងជាភាសាអង់គ្លេសថា «DE MONTFORT UNIVERSITY CAMBODIA » សរសេរជាអក្សរកាត់ថា « DMUC»។

**មាត្រា២.-**

**ស.ឌ.ម.ក** មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣.-**

**ស.ឌ.ម.ក** ជាគ្រឹះស្ថានឧត្តមសិក្សា កម្រិតអន្តរជាតិ ដែលមានស្តង់ដាកម្មវិធីបណ្តុះបណ្តាល ដូចទៅនឹងស្តង់ដាសាកលវិទ្យាល័យនៅចក្រភពអង់គ្លេស និងអនុវត្តសកម្មភាពការអប់រំឧត្តមសិក្សា ដោយផ្អែកលើមូលដ្ឋាននៃកម្មវិធីសិក្សា និងវគ្គសិក្សា ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤.-**

**ស.ឌ.ម.ក** ផ្តល់ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និងក្រោយឧត្តមសិក្សា លើមហាវិទ្យាល័យចំនួន៦ ដូចខាងក្រោម៖

១. មហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងនីតិសាស្ត្រ (Faculty of Business and Law )

២. មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន (Faculty of Information Technology )

៣. មហាវិទ្យាល័យសិល្បៈ និងរចនា (Faculty of Art and Design )

៤. មហាវិទ្យាល័យភាសាអង់គ្លេស (Faculty of English Language Learning )

៥. មហាវិទ្យាល័យអប់រំ (Faculty of Education )

៦. មហាវិទ្យាល័យវិស្វកម្ម (Faculty of Engineering )

នៅពេលអនាគត **ស.ឌ.ម.ក** អាចស្នើសុំបើកសាខា, មហាវិទ្យាល័យថ្មី, ដេប៉ាតឺម៉ង់ថ្មី, មុខជំនាញថ្មី, កម្រិតបណ្តុះបណ្តាលថ្មី, រៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យ, សុំប្តូរឈ្មោះថ្មី, ទីតាំងថ្មី, ឬពង្រីងទីតាំងថ្មី ដោយត្រូវរៀបចំសំណុំបែបបទ សម្រាប់ស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥.-**

**ស.ឌ.ម.ក** ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ស.ឌ.ម.ក** ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦.-**

សាកលវិទ្យាធិការ **ស.ឌ.ម.ក** មានភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ **ស.ឌ.ម.ក** និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

- ទទួលខុសត្រូវក្នុងការទទួលសិស្ស និស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមបទដ្ឋានកំណត់ដោយ **ស.ឧ.ម.ក** និងមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំបង្កើតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិន មុននឹងជ្រើសរើស និស្សិតចូលរៀនឆ្នាំទីមួយ កម្រិតបរិញ្ញាបត្រ
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- គោរព និងអនុវត្តតាមបទដ្ឋាន និងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- បំពាក់សម្ភារៈមូលដ្ឋានសមស្រប ដើម្បីគាំទ្រដល់ការបង្រៀនកម្មវិធី និងវគ្គបណ្តុះបណ្តាល
- ជ្រើសរើសមន្ត្រីបច្ចេកទេស ត្រូវយោងតាមលក្ខខណ្ឌតម្រូវជាក់ស្តែង និងគុណវុឌ្ឍិរបស់បុគ្គល ដូចបានកំណត់ដោយ **ស.ឧ.ម.ក**
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសនីមួយៗ ។

**មាត្រា៧.-**

និស្សិត ដែលរៀនចប់តាមកម្មវិធី និងវគ្គសិក្សា និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយ **ស.ឧ.ម.ក** ផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃ សាកលវិទ្យាល័យ ឌី ម៉ុនហ្វត កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ